ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី
# ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ចំនួន ០២នាក់ និងមិនមានអ្នកជាសះស្បើយ
# នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ ៖

## ១. ស្ថានភាពជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ៖

គិតត្រឹមម៉ោង ០៧:០០ព្រឹកថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជាមាន៖

-ចំនួនអ្នកព្យាបាលជាសះស្បើយសរុបទូទាំងប្រទេស មានចំនួន **៣០៧**នាក់ (ស្មើនឹង ៨៦,២៤% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ-១៩ទាំងអស់) នៅក្នុងចំនួននេះ មានស្រី ៦៣នាក់ និងបុរស ២៤៤នាក់។

- អ្នកមានវីរុសកូវីដ-១៩ មានចំនួនសរុប **៣៥៦**នាក់ (ស្ត្រី ៨៣នាក់ និងបុរស ២៧៣នាក់) ។

- អ្នកសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត រាជធានីភ្នំពេញ ចំនួន **៣៦នាក់** (ស្រី ១៥នាក់ និងបុរស ២១នាក់) ។

-អ្នកសម្រាកព្យាបាលនៅមណ្ឌលសុខភាពចាក់អង្រែ រាជធានីភ្នំពេញ ចំនួន **១៣នាក់** (ស្ត្រី ០៥នាក់ និងបុរស ០៨នាក់) ។

## ២. ករណីវិជ្ជមានវីរុសកូវីដ-១៩ ៖ ចំនួន ០២នាក់

### ២.១. ជាអ្នកដំណើរចូលមកកម្ពុជា ដែលមិនមានពាក់ព័ន្ធទៅនឹង 'ព្រឹត្តិការណ៍សហគមន៍ ២៨វិច្ឆិកា'

-បុរសជនជាតិខ្មែរឈ្មោះ យ៉េ វាសនា អាយុ ២៩ឆ្នាំ មានអាសយដ្ឋានស្នាក់នៅឃុំទួលព្រិច ស្រុកអង្គស្នួល ខេត្តកណ្ដាល គាត់ជាអ្នកធ្វើដំណើរមកពីប្រទេស ជប៉ុន ដោយឆ្លងកាត់ប្រទេសកូរ៉េខាងត្បូង តាមជើងហោះ មកដល់ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០។ ដែលលទ្ធផលធ្វើតេស្តវត្ថុសំណាកលើកទី២ នៅថ្ងៃទី១៣ នៃការធ្វើចត្តាឡីស័ករបស់បុរសនេះ ផ្តល់ដោយវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា រាជធានីភ្នំពេញ គឺ វិជ្ជមានវីរុសកូវីដ-១៩ ហើយបច្ចុប្បន្ន អ្នកជំងឺត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត រាជធានីភ្នំពេញ។

សូមកត់សម្គាល់ថា៖ អ្នកដំណើរតាមយន្តហោះជាមួយអ្នកជំងឺខាងលើ សរុបមានចំនួន ៥០នាក់ ដែលនៅក្នុងចំនួននេះ មានបុគ្គលខាងលើនេះផងដែរ។ មានបុរសចំនួន ០២នាក់ បានធ្វើតេស្តលើកទី២ នៅថ្ងៃទី១៣ នៃការធ្វើចត្តាឡីស័ករបស់ពួកគាត់ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២០ ដែលលទ្ធផលបង្ហាញថា មានបុរសជនជាតិខ្មែរ ០២នាក់ រកឃើញ វិជ្ជមានវីរុសកូវីដ-១៩ ដែលបច្ចុប្បន្ននេះកំពុងសម្រាកនៅមណ្ឌលសុខភាពចាក់អង្រែ រាជធានីភ្នំពេញ។ រីឯ អ្នកដំណើរចំនួន ៤៧នាក់ ដែលមានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ នោះ ត្រូវបានដាក់ឲ្យធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ នៅមណ្ឌលទ័ពអាកាសចំនួន



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

៣៥នាក់ និងនៅសណ្ឋាគារមួយក្នុងរាជធានីភ្នំពេញចំនួន ១២នាក់ ។

**២.២. ជាអ្នកពាក់ព័ន្ធទៅនឹង ព្រឹត្តិការណ៍សហគមន៍ ២៨វិច្ឆិកា**

បុរសជនជាតិខ្មែរឈ្មោះ ខន ប្រសើរ អាយុ ៣៧ឆ្នាំ មានអាសយដ្ឋានស្នាក់នៅសង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ បានទៅហាង Zando សាខាបឹងកេងកង ដែលបានរកឃើញអ្នកមានវីរុសកូវីដ-១៩ ចំនួន ០៥នាក់រួចមកហើយ ដែលកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀតចំនួន ០២នាក់ (ស្រី ០១នាក់ ប្រុស០១នាក់) និងនៅមណ្ឌលសុខភាពចាក់អង្រែចំនួន ០៣នាក់ (ស្រី ០១នាក់ ប្រុស០២នាក់)។ លទ្ធផលធ្វើតេស្តវត្ថុសំណាករបស់បុគ្គលខាងលើនេះ ផ្ដល់ដោយវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា រាជធានីភ្នំពេញ គឺ វិជ្ជមានវីរុសកូវីដ-១៩ ហើយបច្ចុប្បន្នអ្នកជំងឺត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត រាជធានីភ្នំពេញ ។

**៣. មិនមានអ្នកជាសះស្បើយ** នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២០

**៤. លទ្ធផលធ្វើតេស្តអ្នកប៉ះពាល់ក្នុង "ព្រឹត្តិការណ៍សហគមន៍ ២៨វិច្ឆិកា"**

នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០ វត្ថុសំណាកដែលនៅសល់ពីថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២០ ចំនួន ៤,៩៩៤ សំណាក បូកបន្ថែមចំនួនវត្ថុសំណាកទទួលបានបន្ថែមនៅថ្ងៃដដែលពីខេត្ត និងរាជធានីភ្នំពេញដែលជាថ្ងៃធ្វើតេស្តលើកទីពីរសម្រាប់ "ព្រឹត្តិការណ៍សហគមន៍ ២៨ វិច្ឆិកា" សរុបមានចំនួន ៣,៧៩២សំណាក ត្រូវបានធ្វើវិភាគដោយវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា គឺមានលទ្ធផល វិជ្ជមានវីរុសកូវីដ-១៩ ថ្មី ចំនួន ០១នាក់ (ដែលជាអ្នកជំងឺខាងលើនេះ)។ ដោយឡែក មាននៅសល់វត្ថុសំណាកចំនួន ៣,៧២៥សំណាកផ្សេងទៀត ដែលត្រូវវិភាគបន្តនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០។ ពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២០ មកដល់ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០ មានមនុស្សសរុបចំនួន ៣៥នាក់ ហើយដែលត្រូវបានរកឃើញមានវិជ្ជមានវីរុសកូវីដ-១៩។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺឆ្លងសហរដ្ឋអាមេរិក វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា វិទ្យាស្ថានជាតិសុខភាពសាធារណៈ និងមន្ទីរពិសោធន៍នៃមន្ទីរពេទ្យខេត្តសៀមរាប ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃព្រហស្បតិ៍ ១០រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០